# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧១

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបិទបញ្ចប់ផ្នែកជំនុំជម្រះស្តីអំពីការដាក់បទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ ហើយបានផ្តើមស្តាប់សក្ខីកម្មសាក្សីទៅលើប្រធានបទស្តីពីលក្ខណៈនៃជម្លោះប្រដាប់អាវុធ។ ដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយនៃប្រធានបទស្តីពីការដាក់បទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍នេះ គឺអ្នកស្រី **ព្រាប សុខឿន** បានបញ្ចប់សក្ខីកម្មរបស់គាត់ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ហើយបន្ទាប់មក អង្គជំនុំជម្រះក៏បានរៀបចំសវនាការស្តាប់សេចក្តីរងទុក្ខវេទនា និងព្យសនកម្មមកលើជនរងគ្រោះ លើកទីប្រាំផងដែរ។[1]

[1] សវនាការស្តាប់ពីព្យសនកម្មរបស់ជនរងគ្រោះ ត្រូវបានរៀបចំឡើងនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះនីមួយៗ។ សវនាការស្តាប់ពីព្យសនកម្មរបស់ជនរងគ្រោះ អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមិនផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ វគ្គ២ មានឱកាសរៀបរាប់ពីបទពិសោធន៍ស្តីពីការរងទុក្ខវេទនារបស់គាត់ដែលបានទទួលរងគ្រោះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សូមមើល ឯកសាររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "ព័ត៌មានទី១ ស្តីពីសវនាការលើការដាក់បង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង០០២ វគ្គ២ និងព័ត៌មានទី២ ស្តីពីសវនាការស្តាប់ពីព្យសនកម្មរងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ វគ្គ២" (ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤) ឯកសារលេខ E315/1។ សម្រាប់ព័ត៌មានស្តីពីសនាវការស្តាប់ព្យសនកម្មលើកទីមួយនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះលើកទីមួយ ស្តីពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ១៥ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១២ (ចុះថ្ងៃទី៣០ ខែមីនា ដល់ទី៣ ខែមេសា ឆ្នាំ២០១៥) ទំព័រ១ដល់៧។ សម្រាប់សវនាការស្តាប់ព្យសនកម្មលើកទីពីរនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះ ស្តីពីការដ្ឋានការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ២៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៦ (ចុះថ្ងៃទី១ ដល់ទី៣ ខែកញ្ញា ឆ្នាំ២០១៥) ទំព័រ១ដល់៤។ សម្រាប់សវនាការស្តាប់ព្យសនកម្មលើកទីបី ស្តីពីការប្រព្រឹត្តទៅលើក្រុមគោលដៅ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរ

ក្នុងអំឡុងពេលសវនាការ ដែលបានបិទបញ្ចប់នៅថ្ងៃអង្គារ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបីរូប បានផ្តល់សេចក្តីថ្លែងទុក្ខវេទនា ដែលបានទទួលរងគ្រោះក្រោមរបបនេះ ជាពិសេស ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ។ មិនខុសពីសវនាការស្តាប់ព្យសនកម្មរបស់ជនរងគ្រោះមុនៗដែលបានប្រើរយៈពេលលើសពីពីរថ្ងៃ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចរៀបចំសវនាការស្តាប់សេចក្តីថ្លែងទុក្ខវេទនារបស់ជនរងគ្រោះ ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ត្រឹមតែលើសមួយថ្ងៃប៉ុណ្ណោះ ដោយសារតែចំនួនដ៏ច្រើននៃដើមបណ្តឹងរដ្ឋប្បវេណី បានមកផ្តល់សក្ខីកម្មលើប្រធានបទនេះរួចរាល់ទៅហើយ។[2] បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីបានបិទបញ្ចប់សេចក្តីថ្លែងទុក្ខវេទនារបស់ពួកគេរួចមក សាក្សី លោក **ជួន ធី** ដែលត្រូវបានស្នើសុំដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ លោក **ខៀវ សំផន** បានផ្តើមផ្តល់សក្ខីកម្មរបស់លោក ក្នុងរយៈពេលចំនួនមួយថ្ងៃកន្លះ ពាក់ព័ន្ធនឹងលក្ខណៈនៃជម្លោះប្រដាប់អាវុធ។ ដោយហេតុថាគាត់ជាសាក្សីកំពុងស្ថិតក្នុងការស៊ើបសួរក្នុងសំណុំរឿង ០០៣ ដូច្នេះហើយ បានជាត្រូវការពេលវេលាពិចារណានៅពេលចាប់ផ្តើមសក្ខីកម្មរបស់លោក **ជួន ធី** ដើម្បីបញ្ជាក់ថាតើឈ្មោះរបស់គាត់ចាំបាច់ត្រូវការពារ ឬក៏អត់។ នៅទីចុងបញ្ចប់ ត្រូវបានសម្រេចថា សាក្សីរូបនេះគួរតែផ្តល់សក្ខីកម្មដោយបើកចំហវិញ។ ជាទីបញ្ចប់នៅថ្ងៃព្រហស្បតិ៍ សាក្សីលោក **សៅ ម៉ាំង** បានផ្តល់សក្ខីកម្មអំពីលក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់គាត់ក្នុងខេត្តមណ្ឌលគីរី ស្ថិតនៅតំបន់១០៥។

---

ក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៤៥ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៤២ (ចុះថ្ងៃទី២៩ ខែកុម្ភៈ ដល់ទី៣ ខែមីនា ឆ្នាំ ២០១៦) ទំព័រ១ដល់៧។ សម្រាប់សវនាការស្តាប់ព្យសនកម្មលើកទីបួន ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ដែលបានរៀបចំនៅក្នុងខែសីហា ឆ្នាំ២០១៦ សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ២ លេខ៦២ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥៩ (ចុះថ្ងៃទី១១ ដល់១២ ខែសីហា ឆ្នាំ២០១៦) និងរបាយការណ៍លេខ៦៣ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៦០ (ចុះថ្ងៃទី១៥ ដល់១៨ ខែសីហា ឆ្នាំ២០១៦)។

[2] អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនមួយ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ដោយបានបដិសេធនូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យមានការផ្តល់ពេលវេលាបន្ថែមសម្រាប់សវនាការស្តាប់ព្យសនកម្មរបស់ជនរងគ្រោះ ជុំវិញប្រធានបទស្តីពីការដាក់បទប្បញ្ញត្តិរៀបការអាពាហ៍ពិពាហ៍។ ការពិភាក្សាដេញដោលលើបញ្ហានេះ ត្រូវបានសង្ខេបក្នុងរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម លេខ៦៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៦៦ (ចុះថ្ងៃទី១០ ដល់១៣ ខែតុលា ឆ្នាំ ២០១៦) ទំព័រ ១០ ដល់១១។

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាយខល ចេន (Michael Chen), ហាន់ណា ដេយឆ៍ (Hanna Daych), ខេតលីន កាហ្វប្រៀ (Caitlin McCaffrie), និន វុទ្ធី, លូវីស រេតវាយលើ (Louise Rettweiler), តាយ លីណា, ធំ ស្ថាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University